ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ.....០៧២.....អ.ស.ហ.ប្រក

ប្រកាស
ស្តីពី
ការកែសម្រួលប្រការ១១ ប្រការ១៥ ប្រការ១៦ ប្រការ២០ ប្រការ២៦ ប្រការ២៧ ប្រការ២៨ និងប្រការ៣០ នៃប្រកាសលេខ ០០៣ អ.ស.ហ.ប្រក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២៤ ស្តីពីវិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណនិងលិខិតអនុញ្ញាតអាជីវកម្មបញ្ជាំ និងប្រាតិភោគដោយអនុប្បទាន

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១០៨ អនក្រ.បក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
- បានឃើញប្រកាសលេខ ០០៨ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋាន និងអង្គភាពក្រោមឱវាទរបស់និយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ
- បានឃើញប្រកាសលេខ ០០៣ អ.ស.ហ.ប្រក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២៤ ស្តីពីវិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន
- យោងតាមសំណើរបស់អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ

សម្រេច

ប្រការមួយ.-

ប្រការ១១ ប្រការ១៥ ប្រការ១៦ ប្រការ២០ ប្រការ២៦ ប្រការ២៧ ប្រការ២៨ និងប្រការ៣០ នៃប្រកាសលេខ ០០៣ អ.ស.ហ.ប្រក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០២៤ ស្តីពីវិធាន និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណ និងលិខិតអនុញ្ញាតអាជីវកម្មបញ្ចាំ និងប្រាតិភោគដោយអនុប្បទាន ត្រូវបានកែសម្រួលដូចតទៅ៖

ប្រការ១១.-ថ្មី

ន.អ.ប. ឬមន្ទីរ មានសិទ្ធិសម្រេចផ្តល់ ឬបដិសេធចំពោះការស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មក្នុងរយៈពេល ៦ (ប្រាំមួយ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារត្រឹមត្រូវ និងគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវរបស់ **ន.អ.ប**.។ **ន.អ.ប**. ឬមន្ទីរ មានសិទ្ធិចុះពិនិត្យទីតាំងអាជីវកម្មមុនពេលសម្រេចផ្តល់ ឬមិនផ្តល់អាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម។

ក្នុងករណីបដិសេធចំពោះការស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម **ន.អ.ប**. ឬមន្ទីរ ត្រូវជូនដំណឹងទៅក្រុមហ៊ុន ឬសហគ្រាសដែលបានស្នើសុំដោយបញ្ជាក់ហេតុផលជាលាយលក្ខណ៍អក្សរ។

ប្រការ១៥.-ថ្មី

ន.អ.ប. ឬមន្ទីរ ត្រូវចេញលិខិតអនុញ្ញាត ឬលិខិតបដិសេធចំពោះការស្នើសុំដកប្រាក់តម្កល់ធានាអាជីវកម្ម ក្នុងរយៈពេលយ៉ាងយូរ ៦ (ប្រាំមួយ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារត្រឹមត្រូវ និងគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវរបស់ **ន.អ.ប**.។

ប្រការ១៦.-ថ្មី

ការផ្លាស់ប្តូរអាសយដ្ឋានអាជីវកម្ម នាមករណ៍ ភាគហ៊ុនិក សមាសភាពក្រុមប្រឹក្សាភិបាល កម្មវត្ថុអាជីវកម្ម អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម ការបង្កើនដើមទុន ឬការបន្ថយដើមទុន ឬការបង្វែរដើមទុនអាជីវកម្ម ត្រូវស្នើសុំគោលការណ៍អនុញ្ញាតជាមុនពី **ន.អ.ប**. ឬមន្ទីរ។

ន.អ.ប. ឬមន្ទីរ ត្រូវជូនដំណឹងអំពីការអនុញ្ញាត ឬការបដិសេធ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារត្រឹមត្រូវ និងគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវរបស់ **ន.អ.ប**.។

ប្រការ២០.-ថ្មី

ការសម្រេចបន្តសុពលភាព ឬបដិសេធចំពោះការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មត្រូវអនុវត្តតាមនីតិវិធីដូចមានកំណត់ក្នុងប្រការ១១ ថ្មី នៃប្រកាសនេះ។

ន.អ.ប. ឬមន្ទីរ សម្រេចបន្តសុពលភាព ឬបដិសេធចំពោះការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្មក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារត្រឹមត្រូវ និងគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវរបស់ **ន.អ.ប**.។

ក្នុងករណីបដិសេធចំពោះការស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម **ន.អ.ប**. ឬមន្ទីរ ត្រូវជូនដំណឹងទៅក្រុមហ៊ុន ឬសហគ្រាសដែលបានស្នើសុំដោយបញ្ជាក់ហេតុផលជាលាយលក្ខណ៍អក្សរ។

ប្រការ២៦.-ថ្មី

ន.អ.ប. ឬមន្ទីរ ត្រូវចេញលិខិតបញ្ជាក់ការយល់ព្រម ឬបដិសេធសំណើសុំផ្អាក ឬបញ្ឈប់សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន ឬសហគ្រាស បន្ទាប់ពីការត្រួតពិនិត្យសំណុំឯកសារ និង/ឬការវាយតម្លៃជាក់ស្តែងពីមន្ត្រីជំនាញមានសមត្ថកិច្ចរបស់ **ន.អ.ប**. ឬមន្ទីរ នៅក្នុងរយៈពេល ៦ (ប្រាំមួយ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានសំណុំឯកសារត្រឹមត្រូវ និងគ្រប់ចំនួនតាមលក្ខខណ្ឌតម្រូវរបស់ **ន.អ.ប**.។

ក្រុមហ៊ុន ឬសហគ្រាស ដែលត្រូវបានព្យួរ ឬដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម ត្រូវបញ្ឈប់សកម្មភាពអាជីវកម្មបញ្ចាំ និង/ឬប្រាតិភោគដោយអនុប្បទាន ចាប់ពីកាលបរិច្ឆេទចេញលិខិតជាលាយលក្ខណ៍អក្សរដោយ **ន.អ.ប**. ឬមន្ទីរ។

ក្រុមហ៊ុន ឬសហគ្រាស ដែលត្រូវបានព្យួរសកម្មភាពអាជីវកម្ម អាចចាប់ផ្តើមដំណើរការឡើងវិញលុះត្រាតែក្រុមហ៊ុន ឬសហគ្រាសនោះ បានបំពេញកាតព្វកិច្ចស្របតាមបទប្បញ្ញត្តិជាធរមាន និងដាក់ពាក្យស្នើសុំប្រកបអាជីវកម្មឡើងវិញ ដោយមានលិខិតឯកភាពជាលាយលក្ខណ៍អក្សរពី **ន.អ.ប**. ឬមន្ទីរ។

ប្រការ២៧.-ថ្មី

ក្រុមហ៊ុន ឬសហគ្រាស ត្រូវបង់កម្រៃអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម និងកម្រៃសេវារដ្ឋបាលដូចមានកំណត់ទៅតាមប្រភេទ និងចំនួនដូចខាងក្រោម៖

តម្លៃគិតជារៀល

ល.រ	ប្រភេទ		កម្រៃអាជ្ញាបណ្ណ	កម្រៃសេវារដ្ឋបាល	សុពលភាព
-អាជីវកម្មបញ្ចាំ					
១	លិខិតអនុញ្ញាតអាជីវកម្ម	ខ្នាតតូច	១.០០០.០០០	១០០.០០០	១ឆ្នាំ
	អាជ្ញាបណ្ណ	ខ្នាតមធ្យម	១.៨០០.០០០	១៨០.០០០	
		ខ្នាតធំ (កម្រិត១)	២.៧០០.០០០	៥៤០.០០០	
		ខ្នាតធំ (កម្រិត២)	៣.៦០០.០០០	៩០០.០០០	
២	អាជ្ញាបណ្ណសាខា	ខ្នាតមធ្យម	៩០០.០០០	១៣៥.០០០	១ឆ្នាំ
		ខ្នាតធំ (កម្រិត១)	១.៣៥០.០០០	២៧០.០០០	
		ខ្នាតធំ (កម្រិត២)	១.៨០០.០០០	៥៤០.០០០	
-អាជីវកម្មប្រាតិភោគដោយអនុប្បទាន					
១	លិខិតអនុញ្ញាតអាជីវកម្ម	ខ្នាតតូច	៥០០.០០០	៨០.០០០	១ឆ្នាំ
	អាជ្ញាបណ្ណ	ខ្នាតមធ្យម	៩០០.០០០	១៤៤.០០០	
		ខ្នាតធំ (កម្រិត១)	១.៣៥០.០០០	៣៦០.០០០	
		ខ្នាតធំ (កម្រិត២)	១.៨០០.០០០	៤៥០.០០០	
២	អាជ្ញាបណ្ណសាខា	ខ្នាតមធ្យម	៤៥០.០០០	៩០.០០០	១ឆ្នាំ
		ខ្នាតធំ (កម្រិត១)	៦៧៥.០០០	១៨០.០០០	
		ខ្នាតធំ (កម្រិត២)	៩០០.០០០	២២៥.០០០	

ប្រការ២៨.-ថ្មី

ការផ្លាស់ប្តូរអាសយដ្ឋានអាជីវកម្ម នាមករណ៍ ភាគហ៊ុនិក សមាសភាពក្រុមប្រឹក្សាភិបាល កម្មវត្ថុអាជីវកម្ម អ្នកឈរឈ្មោះលើអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតអាជីវកម្ម ការបង្កើនដើមទុន ឬការបន្ថយដើមទុន ឬការបង្វែរដើមទុនអាជីវកម្ម សម្រាប់ក្រុមហ៊ុន ឬសហគ្រាស ដូចមានកំណត់ក្នុងប្រការ១៦ ថ្មី ត្រូវបង់កម្រៃសេវារដ្ឋបាលដូចខាងក្រោម៖

- អាជីវកម្មខ្នាតតូច ចំនួន ៤០០.០០០ (បួនរយពាន់) រៀល ក្នុង ១ (មួយ) ករណី

- អាជីវកម្មខ្នាតមធ្យម ចំនួន ៧២០.០០០ (ប្រាំពីរយម្ភៃពាន់) រៀល ក្នុង ១ (មួយ) ករណី
- អាជីវកម្មខ្នាតធំកម្រិត១ ចំនួន ១.២៦០.០០០ (មួយលានពីររយហុកសិបពាន់) រៀល ក្នុង ១ (មួយ) ករណី
- អាជីវកម្មខ្នាតធំកម្រិត២ ចំនួន ១.៦២០.០០០ (មួយលានប្រាំមួយរយម្ភៃពាន់) រៀល ក្នុង ១(មួយ) ករណី។

ប្រការ៣០.-ថ្មី

ក្រុមហ៊ុន ឬសហគ្រាស ត្រូវបង់ភាគទានប្រចាំឆ្នាំសម្រាប់មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យអចលនវត្ថុ និងវិស័យបញ្ចាំ ដូចមានកំណត់ទៅតាមប្រភេទ និងខ្នាតអាជីវកម្មដូចខាងក្រោម៖

តម្លៃគិតជារៀល

ល.រ	ប្រភេទ	ខ្នាត	ភាគទាន
-អាជីវកម្មបញ្ចាំ			
១	លិខិតអនុញ្ញាតអាជីវកម្ម	ខ្នាតតូច	១០០.០០០
២	អាជ្ញាបណ្ណ	ខ្នាតមធ្យម	២៧០.០០០
		ខ្នាតធំ (កម្រិត១)	៣៦០.០០០
		ខ្នាតធំ (កម្រិត២)	៥៤០.០០០
៣	អាជ្ញាបណ្ណសាខា	ខ្នាតមធ្យម	១៣៥.០០០
		ខ្នាតធំ (កម្រិត១)	១៨០.០០០
		ខ្នាតធំ (កម្រិត២)	២៧០.០០០
-អាជីវកម្មប្រាតិភោគដោយអនុប្បទាន			
១	លិខិតអនុញ្ញាតអាជីវកម្ម	ខ្នាតតូច	៨០.០០០
២	អាជ្ញាបណ្ណ	ខ្នាតមធ្យម	២៧០.០០០
		ខ្នាតធំ (កម្រិត១)	៣៦០.០០០
		ខ្នាតធំ (កម្រិត២)	៥៤០.០០០
៣	អាជ្ញាបណ្ណសាខា	ខ្នាតមធ្យម	១៨០.០០០
		ខ្នាតធំ (កម្រិត១)	២៧០.០០០
		ខ្នាតធំ (កម្រិត២)	៣៦០.០០០

កម្រៃភាគទានដូចមានកំណត់ក្នុងតារាងនៃប្រការនេះ ត្រូវបង់ចូលគណនីរបស់ **ន.អ.ប**.។

ប្រការពីរ.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣.-

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ អគ្គនាយកនៃនិយ័តករ ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៤ កើត ខែ ភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០២៦

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ



អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួលៈ
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងយុត្តិធម៌
-ធនាគារជាតិនៃកម្ពុជា
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ.
"ដើម្បីជូនជ្រាប"
-ដូចប្រការ៣ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ